ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍រីកចំរើនប្រចាំឆ្នាំ២០១៦






**រៀបចំដោយៈ**

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

នៃលេខាធិការដ្ឋាន គ.ជ.អ.ប

ខែធ្នូ ឆ្នាំ២០១៦

# មាតិកា


១. សេចក្តីផ្តើម.....១
២. សកម្មភាព និងលទ្ធផលសម្រេចបាន.....១
២.១ ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៦ ដែលត្រូវការសិក្សាសុវត្ថិភាព.....២
២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៦.....២
២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៦.....៣
២.១.៣.បញ្ជីគម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៦.....៤
២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៦..... ៥
២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់.....៥
២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុក.....៥
២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្ត.....៦
២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៥.....៦
២.៤. ការពង្រឹងសមត្ថភាព.....៧
២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ.....៧
២.៦. ការគាំទ្រ និងកិច្ចសហការ.....៨
៣. បញ្ហាប្រឈមនានា.....៨
៤. ការសន្និដ្ឋាន.....៩
៥. អនុសាសន៍ និងសំណូមពរ.....១០
៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៧.....១០
៧. ឧបសម្ព័ន្ធ៖
៧.១.តារាងតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពគម្រោងឆ្នាំ២០១៦ និងការផ្តល់យោបល់បច្ចេកទេស
៧.២. បញ្ជីឈ្មោះមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច
៧.៣. រូបថតសកម្មភាពក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច

## ១. សេចក្តីផ្តើម

ផែនការអនុវត្តដំណាក់កាលទី១(២០១១-២០១៤) ផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹង និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលក្រុង ស្រុក ឱ្យក្លាយជាស្ថាប័នអភិបាលកិច្ចមូលដ្ឋាន និងអភិវឌ្ឍមូលដ្ឋានយ៉ាងពិតប្រាកដ។ មូលដ្ឋានគ្រឹះសំខាន់ៗ ដូចជារចនាសម្ព័ន្ធ នីតិវិធី ប្រព័ន្ធ និងឧបករណ៍ជាច្រើនសម្រាប់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំឡើងវិញ និងបានផ្តល់ជាបង្អែកយ៉ាងរឹងមាំសម្រាប់ការបោះជំហានឆ្ពោះទៅមុខ។ ទាំងនេះបណ្តាលឱ្យផអ៣ទី១ ក្លាយជាកម្លាំងចលករមួយដ៏សំខាន់សម្រាប់ការងារកំណែទម្រង់និងជាសនិទានកម្មដ៏សំខាន់ដែលនាំឱ្យរាជរដ្ឋាភិបាលបានសម្រេចចិត្តអនុវត្តដំណាក់កាលទី២ (ផអ៣ទី២)តាមរយៈកិច្ចប្រជុំលើកទី១០ របស់គ.ជ.អ.ប. កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ដែលចាប់ផ្តើមពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ ចក្ខុវិស័យនៃផអ៣ទី២នេះ គឺ "*រដ្ឋបាលថ្នាក់ក្រោមជាតិផ្តល់សេវា និងអភិវឌ្ឍមូលដ្ឋានបានកាន់តែច្រើន កាន់តែល្អប្រសើរ កាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរបស់ខ្លួន* "។ ស្រដៀងគ្នានឹងផអ៣ទី១ដែរ ផអ៣ទី២ បានបន្តផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើរដ្ឋបាលក្រុង ស្រុក ប៉ុន្តែក៏មានការពាក់ព័ន្ធជាមួយនឹងថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗទៀតផងដែរ។ ទាក់ទងជាមួយភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ ក្នុងក្របខណ្ឌផអ៣ទី២ នឹងមិនអនុវត្តដោយអនុកម្មវិធីទៀតទេ។ ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ គឺជាក្រសួងស្ថាប័នទាំងឡាយណាដែលមានការពាក់ព័ន្ធជាមួយការងារកំណែទម្រង់ ជាពិសេសការផ្ទេរមុខងារ និងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយការផ្តួចផ្តើមសំដៅសម្រេចបានដោយជោគជ័យក្នុងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចក្ខុវិស័យសម្រាប់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការប្រើប្រាស់ធនធានទាំងអស់ដែលមានរួមទាំងមន្ត្រីរាជការស៊ីវិល បុគ្គលិកកិច្ចសន្យា ទាំងផ្នែកឯកជន និងអង្គការសង្គមស៊ីវិល។ ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅរាជធានី ខេត្ត គឺជាយន្តការថ្មីមួយទៀតនៃផអ៣ទី២ ដែលសង្ឃឹមថានឹងធានាបាននូវការរៀបចំវិធីសាស្ត្រនៃការអភិវឌ្ឍសមត្ថភាពដែលមានលក្ខណៈឆ្លើយតបទៅនឹងសមិទ្ធផលទាំងប្រាំរបស់ផអ៣ទី២គឺ៖១). ការគ្រប់គ្រងកំណែទម្រង់ ២). គណនេយ្យភាពបែបប្រជាធិបតេយ្យ ៣). ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ៤). កាផ្ទេរមុខងារ និងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង៥). វិមជ្ឈការហិរញ្ញវត្ថុ ។

កិច្ចការពារសុវត្ថិភាពជាយន្តការមួយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ។ យន្តការមួយនេះ ត្រូវបានប្រើប្រាស់នៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងទាំងបីប្រភេទ ដែលតម្រូវឱ្យអ្នកអនុវត្តគម្រោងត្រូវតែមានការប្រុងប្រយ័ត្នជាមុនលើហានិភ័យដែលអាចកើតមានឡើងដោយសារការអនុវត្តគម្រោងលើកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មានន័យថា គោលបំណងសំខាន់នៃកិច្ចការពារសុវត្ថិភាពទាំងនេះ គឺបញ្ចៀសបាន ឬកាត់បន្ថយបានជាអប្បបរមា ឬក៏សម្រាលបន្ទុកនៃផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាន ឬចំណាយសង្គម ចំពោះភាគីទីបី ឬពុំអើពើចំពោះក្រុមជនងាយរងគ្រោះ ដែលអាចទទួលរងឥទ្ធិពលពីការអនុវត្តគម្រោងអភិវឌ្ឍន៍មូលដ្ឋាន។

កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច បានក្លាយជាប្រធានបទមួយយ៉ាងសំខាន់សម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ដែលលេខាធិការដ្ឋាន គ.ជ.អ.ប បានពិចារណាយ៉ាងល្អិតល្អន់លើដំណោះស្រាយបញ្ហាបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចជាអាទិភាពសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ទាំងអស់នៅថ្នាក់ក្រោមជាតិ។

## ២. សកម្មភាព និងលទ្ធផលសម្រេចបាន

ក្នុងឆ្នាំ២០១៦នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបានអនុវត្តន៍តាមផែនការសកម្មភាព និងថវិកាដែលបានលើកឡើង ហើយសម្រេចបានលទ្ធផលមួយចំនួនមានដូចជា៖ តាមរយៈការប្រជុំឆ្លុះបញ្ចាំង និងតាមរយៈវគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិផ្សារភ្ជាប់ជាមួយវគ្គបណ្តុះបណ្តាលរំលឹក

ឡើងវិញផ្នែកសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដល់មន្ត្រីបច្ចេកទេសដែលទើបចូលបម្រើការងារថ្មី និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចថ្នាក់ខេត្តពីដំណើរការ និងគោលការណ៍នៃការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ព្រមទាំងបានចែករំលែកមេរៀន និងបទពិសោធន៍ល្អៗដល់អ្នកពាក់ព័ន្ធនានាផងដែរ។ ការពិនិត្យ និងផ្តល់យោបល់បច្ចេកទេសជំហានដំបូងមុនការអនុវត្តដេញថ្លៃគម្រោងលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាននិងរបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច ព្រមទាំងការចុះពង្រឹងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងដីធ្លីជាក់ស្តែងនៅតាមបណ្តាឃុំសង្កាត់និងនៅទីតាំងគម្រោង ដោយបានជួបជាមួយមន្ត្រីពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ទីប្រឹក្សាខេត្ត ទីប្រឹក្សាក្រុង ទីប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ ជាមួយគ្នានេះដែរ ក្រុមការងារបានសម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៦ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានសិក្សាមុននឹងអនុវត្តន៍គម្រោង។ក្រុមការងារបានចូលរួមសម្របសម្រួលនិងផ្សព្វផ្សាយក្នុងវគ្គបណ្តុះបណ្តាលស្តីពីគម្រោងសេវាកម្មក្រុងស្រុកដល់មន្ត្រីនិងទីប្រឹក្សានៅថ្នាក់ក្រោមជាតិចំនួនពីរលើកនៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម។

## ២.១.ការពិនិត្យបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត ឆ្នាំ២០១៦ ដែលត្រូវការសិក្សាសុវត្ថិភាព ៖

### ២.១.១. បញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៦ ៖

គម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៦ មានចំនួនសរុប**១៦២១**គម្រោងនៃ**១៥៣៧** ឃុំ សង្កាត់ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៥៨**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**៤៦៥**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបចំនួន **៨៥**គម្រោង។ គម្រោងមូលនិធិឃុំ សង្កាត់ ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប **៥៦១** និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចមានចំនួនសរុប **៨៥**គម្រោង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤ ។ គម្រោងរាជធានីភ្នំពេញមិនមាននៅក្នុងបញ្ជីទេ ដោយសារមិនបានប្រើប្រាស់មូលនិធិឃុំសង្កាត់របស់លេខាធិការដ្ឋាន គ.ជ.អ.ប. ។

*រូបភាពទី១៖ ក្រាហ្វិចចំនួនឃុំសង្កាត់ និងចំនួនគម្រោងតម្រូវការសិក្សាសុវត្ថិភាព*



នៅក្នុងគម្រោងសរុបចំនួន១៦២១នេះ មានផ្លូវគ្រប់ប្រភេទចំនួន ១៣៨៦ខ្សែ ស្ពានចំនួន ២៩កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងទំនប់ចំនួន ១៥៤កន្លែង អណ្តូងស្នប់ និងស្រះជីកចំនួន ២៦កន្លែង សាលារៀនចំនួន៨កន្លែង បង្គន់អនាម័យមាន១កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ លូរំដោះទឹក សំណង់ទីទួលសុវត្ថិភាព សំណង់ស្ថានីយ៍បូមទឹក ផែសហគមន៍ រនេលស្ទាក់ទឹក និងរ៉ែទឹកចំនួន ៤៩កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

រូបភាពទី២៖ ក្រាហ្វិចឈ្មោះគម្រោង និងចំនួនគម្រោងឃុំ សង្កាត់ ឆ្នាំ២០១៦




## ២.១.២. បញ្ជីគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៦ ៖

គម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៦ មានចំនួនសរុប១៩៤ គម្រោង នៃ ១៥៤ក្រុង ស្រុក ក្នុង១៩ខេត្ត។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ១០៨គម្រោង មិនមានតម្រូវការសិក្សាដីធ្លីទេ តម្រូវការសិក្សាជនជាតិដើមភាគតិចមាន ២៨គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុប៩៥។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងមូលនិធិក្រុង ស្រុក ដែលបានស្នើឡើង ។

រូបភាពទី៣៖ ក្រាហ្វិចចំនួនក្រុង ស្រុក និងតម្រូវការសិក្សាសុវត្ថិភាព




នៅក្នុងគម្រោងសរុបចំនួន១៩៤នេះ មានផ្លូវក្រួសក្រហម និងផ្លូវបេតុងអាមេចំនួន១០៧ខ្សែ ស្ពានចំនួន ៦កន្លែង ប្រព័ន្ធធារាសាស្ត្រមានប្រឡាយ និងទំនប់ចំនួន ៧កន្លែង អណ្តូងស្នប់ចំនួន ១កន្លែង ជួសជុលអគាររដ្ឋបាលនិងអគារក្រុមប្រឹក្សាចំនួន ១៣កន្លែង បង្គន់មាន១កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូកាត់ផ្លូវ

លូរំដោះទឹក កែលម្អសួនច្បារ របងអាគារ ចាក់សាបទីធ្លាសាធារណៈ គ្រប់គ្រងសំណល់ តបណ្តាញអគ្គីសនីសាធារណៈចំនួន **៦០**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្ត។

**រូបភាពទី៤៖ ក្រាហ្វិចឈ្មោះគម្រោងក្រុង ស្រុក និងចំនួនគម្រោង**




**២.១.៣.បញ្ជីគម្រោងមូលនិធិខេត្ត ឆ្នាំ២០១៦ ៖**

គម្រោងមូលនិធិខេត្តដែលបានស្នើឡើងសម្រាប់អនុវត្តនៅឆ្នាំ២០១៦ មានចំនួនសរុប **១៤២**គម្រោងនៃខេត្តទាំង២៤ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន **២២**គម្រោង មិនមានតម្រូវការសិក្សាដីធ្លីទេ និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមានចំនួន**១**។ គម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានមានចំនួនសរុប២១។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោងខេត្ត ដែលបានស្នើឡើងនៅតាមបណ្តាខេត្តទាំង២៤ ។

**រូបភាពទី៥៖ ក្រាហ្វិចចំនួនគម្រោងខេត្ត និងតម្រូវការសិក្សាសុវត្ថិភាព**




នៅក្នុងគម្រោងសរុបចំនួន១៤២នេះ មានផ្លូវគ្រប់ប្រភេទចំនួន **២៧**ខ្សែ ប្រព័ន្ធធារាសាស្ត្រមានចំនួន **២**គម្រោង អណ្តូងចំនួន**១**កន្លែង អគាររដ្ឋបាលចំនួន**៥**កន្លែង និងផ្សេងៗដែលមានប្រព័ន្ធលូ ជួសជុល និងសាងសង់បង្គោលភ្លើងបំភ្លឺផ្លូវ ថែលម្អសួនច្បារសោធារណៈចំនួន **៧៦**កន្លែង។ ក្រាហ្វិចខាងក្រោមបង្ហាញពីចំនួនគម្រោង និងឈ្មោះគម្រោងដែលបានអនុវត្តន៍។

រូបភាពទី៦៖ ក្រាហ្វិចឈ្មោះគម្រោងខេត្ត និងចំនួនគម្រោង




២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោង ឆ្នាំ២០១៦៖

២.២.១.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថានចំនួនសរុប **៥៤៧**គម្រោង ស្មើនឹង**៩៣%**នៃចំនួនសរុប **៥៨៨**គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារជនជាតិដើមភាគតិចចំនួន **៧៦**គម្រោង ស្មើនឹង **៦១%**នៃចំនួន**៨៩**គម្រោង ដែលស្ថិតក្នុងបញ្ជីជនជាតិដើមភាគតិច។ ក្នុងនេះ គម្រោងបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុនៅមូលដ្ឋានមានចំនួន **៩**គម្រោង។

រូបភាពទី៧៖ ក្រាហ្វិចចំនួនគម្រោងឃុំ សង្កាត់ និងភាគរយដែលបានពិនិត្យនិងផ្តល់យោបល់




២.២.២.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៦៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិក្រុង ស្រុក លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួនសរុប **៥៤**គម្រោងស្មើនឹង**៥៧%**នៃចំនួនសរុប **៩៥**គម្រោង និងរបាយការណ៍ការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន៨គម្រោង នៃ២៥គម្រោងស្មើនិង**៣២%**។

រូបភាពទី៨៖ ក្រាហ្វិចចំនួនគម្រោងក្រុង ស្រុក និងភាគរយដែលបានពិនិត្យ



២.២.៣.ការពិនិត្យ និងការផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិរាជធានី ខេត្តឆ្នាំ២០១៦៖

បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថានចំនួន ១៨គម្រោង ស្មើនឹង៨៦%នៃចំនួន២១គម្រោង និងផ្តល់យោបល់បច្ចេកទេសលើវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចចំនួន១គម្រោងស្មើ១០០%នៃចំនួន ១គម្រោង។

រូបភាពទី៩៖ ក្រាហ្វិចចំនួនគម្រោងខេត្ត និងភាគរយដែលបានពិនិត្យ




២.៣.ការត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីក្រោយពេលដេញថ្លៃគម្រោងឆ្នាំ២០១៥ ៖

បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចំនួនប្រាំបីខេត្ត ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ ក្នុងខេត្តទាំងប្រាំបីនេះ បានត្រួតពិនិត្យគម្រោង ដីធ្លីសរុបចំនួន ១៤០គម្រោង ស្មើនឹង៦៣%នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន ២២២គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ ធ្វើឡើងនៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានប្រជុំឆ្លុះបញ្ចាំងដោយបង្ហាញពីលទ្ធផលដែលបានរកឃើញដល់នាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគ ព្រមទាំងមន្ត្រីទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត និងទីប្រឹក្សាខេត្តពាក់ព័ន្ធ ដើម្បីផ្តល់យោបល់លើចំណុចខ្វះខាតដែលជាមេរៀននិងបទពិសោធន៍សម្រាប់អនុវត្តនៅឆ្នាំក្រោយៗទៀត។ តារាងខាងក្រោមបង្ហាញពីចំនួនឯកសាររបាយការណ៍សិក្សាដីធ្លី ដែលក្រុមការងារបានត្រួតពិនិត្យ។

តារាងទី១៖ ចំនួនគម្រោងឆ្នាំ២០១៥ ដែលសិក្សាដីធ្លី និងភាគរយដែលបានចុះត្រួតពិនិត្យ

| ល.រ | ឈ្មោះខេត្ត | គម្រោងសរុប | គម្រោង សិក្សាដីធ្លី | គម្រោងត្រូវបានពិនិត្យ | ចំនួន% |
|---|---|---|---|---|---|
| ១ | ស្វាយរៀង | ៩៤ | ៤៤ | ២៦ | ៥៩% |
| ២ | កំពង់ឆ្នាំង | ៦៨ | ៣៧ | ២៨ | ៧៥% |
| ៣ | កំពង់ស្ពឺ | ១០០ | ១៤ | ១៤ | ១០០% |
| ៤ | រតនគិរី | ៦៨ | ៣៧ | ២៨ | ៧៥% |
| ៥ | កំពង់ធំ | ៨៤ | ៤៩ | ២២ | ៤៥% |
| ៦ | ព្រះវិហារ | ៥០ | ៣២ | ១៤ | ៦៦% |
| ៧ | មណ្ឌលគិរី | ២១ | ៧ | ៦ | ៨៥% |
| ៨ | បាត់ដំបង | ១១៩ | ២ | ២ | ១០០% |
| សរុប | | ៦០៤ | ២២២ | ១៤០ | ៦៣% |

## ២.៤. ការពង្រឹងសមត្ថភាព៖

- ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៥ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ នៃគ.ជ.អ.ប. នៅខេត្តព្រះសីហនុ។
- ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ បានចូលរួមក្នុងកិច្ចប្រជុំសម្រេចលើផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ របស់លេខាធិការដ្ឋាន គ.ជ.អ.ប. នៅសាលប្រជុំរបស់លេខាធិការដ្ឋាន។
- ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៦ បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយនិងកសាងសមត្ថភាពស្តីពីការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ក្រោមជាតិដែលឧបត្ថម្ភដោយគម្រោង LGCC II គាំទ្រដោយអង្គការ UNCDF ប្រចាំកម្ពុជា រៀបចំនៅខេត្តព្រះសីហនុ។
- ថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១៥ បានចូលរួមក្នុងសិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ នៃគ.ជ.អ.ប. នៅសាលប្រជុំក្រសួងមហាផ្ទៃ។
- ថ្ងៃទី៣០-៣១ ខែមីនា ឆ្នាំ២០១៦ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន និងសុវត្ថិភាពសង្គម ទាក់ទងទៅនឹងការប្រែប្រួលអកាសធាតុ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ក្នុងរាជធានីភ្នំពេញ។
- ថ្ងៃទី២៦-២៩ ខែមេសា ឆ្នាំ២០១៦ បានចូលរួមក្នុងវគ្គផ្សព្វផ្សាយ និងកសាងសមត្ថភាពស្តីពីការបញ្ជ្រាបការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ក្រោមជាតិ បន្តដល់គ្រូបង្គោលតាមស្រុកគោលដៅទាំងប្រាំបី ដែលរៀបចំដោយគម្រោង LGCC II គាំទ្រដោយអង្គការ UNCDF ប្រចាំកម្ពុជា ដែលបានរៀបចំនៅខេត្តព្រះសីហនុ។
- ថ្ងៃទី៣០- ៣១ ខែមេសា ឆ្នាំ២០១៦ បានចូលរួមក្នុងសិក្ខាសាលាវាយតម្លៃការអនុវត្តមូលនិធិ PBCR Grant និងវាយតម្លៃគម្រោងតាមបែបចូលរួមរបស់ក្រុងស្រុកគោលដៅរបស់គម្រោង LGCC II នៅខេត្តតាកែវ និងខេត្តបាត់ដំបង ដែលរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយអង្គការ UNCDF នៅខេត្តសៀមរាប។

## ២.៥. សកម្មភាពពង្រឹងសមត្ថភាពដល់ថ្នាក់ក្រោមជាតិ៖

- ថ្ងៃទី១-៤ ខែមីនា ឆ្នាំ២០១៦ នៅខេត្តបាត់ដំបង និងនៅថ្ងៃទី៩-១១ ខែមីនា ឆ្នាំ២០១៦ នៅខេត្តកំពង់ចាម បានចូលរួមសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលបន្តដល់មន្ត្រី និងទីប្រឹក្សាថ្នាក់ក្រោមជាតិ អំពីការរៀបចំគម្រោងសេវាកម្មក្រុងស្រុកជាមួយមន្ត្រី និងទីប្រឹក្សារបស់នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ដោយមានការឧបត្ថម្ភពីអង្គការ UNICEF និង UNFPA នេះ មានចំនួនពីរវគ្គ គឺវគ្គទី១នៅខេត្តបាត់ដំបង មានអ្នកចូលរួមចំនួន៦៣នាក់ក្នុងនេះស្ត្រី៩នាក់ ដែលអញ្ជើញមកពីខេត្តចំនួន១៣ និង វគ្គទី២នៅខេត្តកំពង់ចាមមានអ្នកចូលរួមចំនួន៦៣នាក់ ក្នុងនេះស្ត្រី៩នាក់ ដែលអញ្ជើញមកពីខេត្តចំនួន១៣ដែរ ។ សមាសភាពចូលរួមវគ្គបណ្តុះបណ្តាលរួមមាន៖ មន្ត្រីនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ទីប្រឹក្សាថ្នាក់ជាតិ និងនាយក នាយករងទីចាត់ការផែនការ និងវិនិយោគ នាយក នាយករងទីចាត់ការគ្រប់គ្រងធនធានមនុស្ស ប្រធាន អនុប្រធានការិយាល័យផែនការគ្រប់គ្រងឃុំសង្កាត់ ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ ទីប្រឹក្សាកសាងនិងអភិវឌ្ឍន៍សមត្ថភាព និងមន្ត្រីបច្ចេកទេសខេត្ត ។ វគ្គបណ្តុះបណ្តាលនេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗបីគឺ៖ (១)បង្កើនចំណេះដឹង ជំនាញ និងសមត្ថភាពក្នុងការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក (២)បង្កើនសមត្ថភាពដល់គ្រូបង្គោលដើម្បីបណ្តុះបណ្តាលបន្តដល់រដ្ឋបាលក្រុង ស្រុក (៣)ផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការរៀបចំគម្រោងសេវាកម្មក្រុង ស្រុក ។

## ២.៦. ការគាំទ្រ និងកិច្ចសហការៈ

- ក្រុមការងារបានសម្របសម្រួលជាមួយទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្តទាំងអស់ដើម្បីពន្លឿនការសិក្សាកិច្ចការពារសុវត្ថិភាពទាំងបី និងដើម្បីផ្ញើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងជនជាតិដើមភាគតិច មកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេសគម្រោងឲ្យទាន់ពេលវេលាដេញថ្លៃ និងបានឆ្លើយតបតាមតម្រូវការជាក់ស្តែងនៅមូលដ្ឋាន ។
- ក្រុមការងារបានសហការជាមួយមន្ត្រី និងទីប្រឹក្សា នៃនាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃក្រសួងមហាផ្ទៃ បញ្ចូលវគ្គរំលឹកឡើងវិញស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងគម្រោងមូលនិធិឃុំ សង្កាត់ ក្រុង ស្រុក និងរាជធានី ខេត្ត វគ្គបណ្តុះបណ្តាលស្តីពីមូលដ្ឋានគ្រឹះគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ក្រោមជាតិដល់មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធដែលទើបចូលបម្រើការងារថ្មី ដែលបានរៀបចំឡើងនៅខេត្តកំពង់ចាម ព្រមទាំងបានជួយសម្របសម្រួលក្នុងវគ្គបណ្តុះបណ្តាលនេះផងដែរ ។
- បានចូលរួមវាយតម្លៃការអនុវត្តមូលនិធិ PBCR Grant និងវាយតម្លៃគម្រោងតាមបែបចូលរួមរបស់ក្រុងស្រុកគោលដៅរបស់គម្រោង LGCC II នៅខេត្តតាកែវ និងខេត្តបាត់ដំបង ជាមួយអង្គការ UNCDF នៅក្រុង ស្រុកចំនួន៨ ដែលបានអនុវត្តគម្រោងរួចហើយក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥ ដើម្បីបានទទួលមូលនិធិអនុវត្តន៍គម្រោងបន្តនៅឆ្នាំ២០១៧ទៀត។

# ៣. បញ្ហាប្រឈមនានា

ក្នុងឆ្នាំនេះ ការសិក្សាផលប៉ះពាល់មានភាពយឺតយ៉ាវ រហូតដល់ខែមេសាទើបមានខេត្តមួយចំនួនបានផ្ញើឯកសារគម្រោង របាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងរបាយការណ៍វិធានការការពារជនជាតិដើមភាគតិចមកក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចដើម្បីពិនិត្យ និងផ្តល់យោបល់បច្ចេកទេស ដែលជាហេតុនាំឱ្យមានការដេញថ្លៃយឺតយ៉ាវ មូលហេតុទាំងនេះមកពីខេត្តទាំងនោះមានឧបករណ៍ សម្ភារៈ និងមធ្យោបាយចាស់ៗពេក និងខ្លះខូចប្រើការមិនកើតនាំឱ្យយឺតយូរក្នុងការសិក្សាគម្រោង។ ដូចឆ្នាំមុនដែរ ខេត្តមួយចំនួនបានធ្វើការសិក្សាផលប៉ះពាល់បរិស្ថាននិងវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច មុនពេលធ្វើតម្រូវការសិក្សាគម្រោង និងធ្វើផែនការគម្រោង ដែលខុសនឹងនីតិវិធីដែលមានចែងក្នុងសៀវភៅ(ភីម) នាំឱ្យមានការរៀបចំឯកសារម្តងហើយម្តងទៀត។ បញ្ហាប្រឈមមួយចំនួនដែលក្រុមការងារបានរកឃើញក្នុងការពិនិត្យឯកសារគម្រោងដីធ្លី និងចុះទៅដល់ទីតាំងគម្រោងមានដូចខាងក្រោមៈ

- បំពេញទម្រង់នានានៅតែមានភាពខ្វះចន្លោះច្រើន ពិសេសការគូរផែនទីអង្កេតដីធ្លីនៅមិនទាន់បានត្រឹមត្រូវ។
- ឃុំ សង្កាត់មួយចំនួនមិនបានរក្សាឯកសារច្បាប់ដើមរបស់គម្រោងនៅសាលាឃុំ សង្កាត់។
- ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនភាគច្រើននៅមិនទាន់យល់ច្បាស់អំពីដំណើរការនៃការសិក្សា និងការរៀបចំឯកសារគម្រោងពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពដីធ្លីនៅឡើយ។
- មន្ត្រីទទួលបន្ទុកលើការងារផ្នែកបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោងមានការផ្លាស់ប្តូរជារៀងរាល់ឆ្នាំ ធ្វើឲ្យមន្ត្រីថ្មីមិនសូវយល់ពីការសិក្សាសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចរបស់គម្រោង ។
- មន្ត្រីបច្ចេកទេស និងមន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់នៅមិនទាន់ចុះជួយគាំទ្រគម្រោងឱ្យបានជិតដល់នៅឡើយ ដោយសារមន្ត្រីនីមួយៗមានការងារស្មុគស្មាញច្រើន និងមានថវិកាមិនគ្រប់គ្រាន់សម្រាប់ចុះសិក្សាគម្រោង ព្រមទាំងមិនមានការលើកទឹកចិត្តខ្លះៗ។

- ឧបករណ៍ សម្ភារៈ និងមធ្យោបាយមានសភាពចាស់ៗ និងខ្លះខូចនាំឱ្យមានការលំបាកប្រើប្រាស់ក្នុងការសិក្សាគម្រោង ។
- ខេត្តខ្លះមានអ្នកបច្ចេកទេស និងមន្ត្រីទីចាត់ការផែនការ និងវិនិយោគនៅមិនទាន់សហការគ្នាល្អក្នុងការសិក្សាសុវត្ថិភាពរបស់គម្រោងនៅឡើយ។
- ការិយាល័យគាំទ្រក្រុង ស្រុក នៅខ្វះមន្ត្រីជួយគាំទ្រគម្រោង ហើយមន្ត្រីទាំងនោះជាមន្ត្រីថ្មីដែលនៅមិនទាន់បានឆ្លងកាត់វគ្គណាមួយនៅឡើយ ។
- មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចភាគច្រើនមិនបានចុះជួយសិក្សាសុវត្ថិភាពគម្រោងដោយផ្ទាល់ទេ ដោយសារមិនមានថវិកាចុះទៅទីតាំងគម្រោងដូចពេលមុនៗ ។
- ស្មៀនឃុំសង្កាត់មួយចំនួនជិតចូលនិវត្តន៍មិនសូវយកចិត្តទុកដាក់ក្នុងការសិក្សាគម្រោង ស្មៀនដែលចូលបម្រើការងារថ្មីនៅមិនទាន់បានយល់ពីការសិក្សាសុវត្ថិភាពរបស់គម្រោងនៅឡើយ។
- ការកែសម្រួលឯកសារគម្រោងពីថ្នាក់ឃុំសង្កាត់មកក្រុងស្រុករហូតដល់ខេត្តប្រើរយៈពេលយូរ ជាហេតុនាំឱ្យយឺតយូរក្នុងការដេញថ្លៃគម្រោង។

## ៤. ការសន្និដ្ឋាន

ក្នុងឆ្នាំ២០១៦នេះ ក្រុមការងារបានអនុវត្តការងារស្របទៅតាមផែនការសកម្មភាព ដែលបានគ្រោងទុកមានដូចជា ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើការអនុវត្តសុវត្ថិភាពបរិស្ថាន និងជនជាតិដើមភាគតិចរបស់គម្រោងឆ្នាំ២០១៦មុនដេញថ្លៃ ត្រួតពិនិត្យឯកសាររបាយការណ៍ និងការអនុវត្តសុវត្ថិភាពដីធ្លី គម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុកឆ្នាំ២០១៥ដែលបានអនុវត្តគម្រោងរួចរាល់ ចុះត្រួតពិនិត្យឯកសាររបាយការណ៍និងការអនុវត្តការវិភាគបរិស្ថានរបស់គម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៦ ដើម្បីប្រាកដថាបានអនុវត្តន៍តាមការណែនាំដែរឬទេ។ តាមរយៈការចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនេះ ក្រុមការងារបានជួបជាមួយអ្នកពាក់ព័ន្ធ រួមទាំងចុះអង្កេតផ្ទាល់ដល់ទីតាំងគម្រោង។ ខេត្តមួយចំនួនដែលក្រុមការងារបានចុះត្រួតពិនិត្យគម្រោងក្នុងឆ្នាំ២០១៥ ឃើញថា ខេត្តដែលធ្លាប់បានចុះត្រួតពិនិត្យក្នុងឆ្នាំកន្លងទៅមានការកែប្រែក្នុងកម្រិតល្អមួយ តាមរបកគំហើញដែលបានឆ្លុះបញ្ចាំងក្នុងអំឡុងពេលចុះបេសកកម្ម ។ ដោយឡែកខេត្តមួយចំនួនដែលមានការផ្លាស់ប្តូរមន្ត្រីជាញឹកញាប់ក្រុមការងារបានរកឃើញមានការបំពេញឯកសាគម្រោងនៅតែមានភាពខ្វះចន្លោះច្រើនដដែល ឯកសារទាំងនោះមានដូចជា បំពេញទម្រង់ទី១ និងទី២ ក្រោយការសិក្សាផលប៉ះពាល់បរិស្ថាន និងដីធ្លីដែលផ្ទុយពីគោលការណ៍ណែនាំរបស់សៀវភៅ(ភីម) គូរផែនទីអង្កេតដីធ្លីនៅមិនទាន់ត្រឹមត្រូវ ដោយមិនបានបង្ហាញក្បាលដីនីមួយៗដែលប៉ះពាល់ដោយគម្រោង មិនបានបញ្ជាក់និងប្រថាប់ត្រានៅគ្រប់សន្លឹកក្នុងទម្រង់ទី២០.៥ ការចុះកាលបរិច្ឆេទលើទម្រង់របាយការណ៍ដោយកុំព្យូទ័រទុកជាមុន ប្រជុំផ្សព្វផ្សាយគម្រោងបរិច្ចាគដីធ្លី និងទ្រព្យសម្បត្តិដោយស្ម័គ្រចិត្ត និងប្រជុំពិភាក្សានិងព្រមព្រៀងរៀបចំដំណាលគ្នាក្នុងថ្ងៃតែមួយ ត្រួតពិនិត្យការសិក្សាព័ត៌មានគម្រោងដោយទីចាត់ការផែនការនិងវិនិយោគខេត្តបានធិកដោយកុំព្យូទ័រទុកជាមុន ក្នុងរបាយការណ៍បរិច្ចាគដីធ្លីដោយស្ម័គ្រចិត្ត(ទម្រង់ទី២០.៩)បានបំពេញទិន្នន័យមិនគ្រប់គ្រាន់ មានឃុំខ្លះចុះអង្កេតដីធ្លីមានចំនួនប្រជាពលរដ្ឋចូលរួមតិចតួច ការបំពេញទម្រង់របាយការណ៍វិភាគបរិស្ថានរបស់គម្រោងក្រុង ស្រុក និងគម្រោងខេត្តនៅមានការខ្វះចន្លោះច្រើន គឺការបំពេញទម្រង់មិនតាមលំដាប់លំដោយ។ ជាមួយគ្នានឹងការបំពេញឯកសារខ្វះចន្លោះនេះ ខេត្តនីមួយៗជួបនូវបញ្ហាមួយចំនួន ដូចជា ខ្វះឧបករណ៍សម្ភារៈប្រើប្រាស់សម្រាប់សិក្សាគម្រោង មានមន្ត្រីមិនគ្រប់គ្រាន់ជួយគាំទ្រគម្រោង និងពុំសូវមានកិច្ចសហការគ្នាល្អរវាងទីចាត់ការផែនការ និងវិនិយោគ និងមន្ទីរជំនាញពាក់ព័ន្ធ។ មានខេត្តខ្លះបានអនុវត្តន៍វិភាគផលប៉ះពាល់បរិស្ថាន និងសិក្សាដីធ្លីរបស់គម្រោងម្ចាស់ការដោយខ្លួនឯងជាបណ្តើរៗ។

## ៥. អនុសាសន៍ និងសំណូមពរ

ដើម្បីពង្រឹងការអនុវត្តសកម្មភាពកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ និងដើម្បីឆ្លើយតបតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅភីម និងលិខិតណែនាំនានា លុះត្រាតែះ

- បង្កើនការយកចិត្តទុកដាក់ពីមន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធ ជាពិសេស ការតាមដាន ត្រួតពិនិត្យពីសំណាក់ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត និងទីប្រឹក្សាពង្រឹងសមត្ថភាព ទាំងការរៀបចំទុកដាក់ឯកសារ និងការអនុវត្តជាក់ស្តែង ព្រមទាំងផ្តល់ការហ្វឹកហ្វឺនបន្ថែមដល់ទីប្រឹក្សាក្រុង ស្រុក មន្ត្រីបច្ចេកទេសគាំទ្រឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត ។

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះការសិក្សា ការរៀបចំឯកសារគម្រោងឱ្យបានត្រឹមត្រូវតាមគោលការណ៍ណែនាំ និងលិខិតបទដ្ឋាននានា ព្រមទាំងបង្កើននូវការតាមដាន ត្រួតពិនិត្យពេលអនុវត្តន៍គម្រោង និងថែទាំលទ្ធផលគម្រោងឱ្យបានជាប់ជាប្រចាំ ។

- មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្ត និងមន្ត្រីបច្ចេកទេសគាំទ្រឃុំសង្កាត់ត្រូវបង្កើនកិច្ចសហការគ្នាចុះតាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោងឱ្យបានជិតដល់ ។

- មន្ត្រីគាំទ្រគម្រោងដែលទទួលខុសត្រូវនៅក្នុងឃុំសង្កាត់របស់ខ្លួន ត្រូវខិតខំស្វែងយល់ពីការសិក្សាសុវត្ថិភាពគម្រោងឲ្យស្ទាត់ជំនាញសម្រាប់ជួយគាំទ្រគម្រោង ។

- ខេត្តគួរពិចារណាពិនិត្យលទ្ធភាពបណ្តុះបណ្តាលដល់មន្ត្រីថ្មី និងទីប្រឹក្សាក្រុង ស្រុកពីកិច្ចការពារសុវត្ថិភាពឱ្យបានពីរដងក្នុងមួយឆ្នាំ ។

- ខេត្តគួរពិនិត្យលទ្ធភាពក្នុងផ្តល់ការហ្វឹកហ្វឺនបន្ថែមទៀតដល់មន្ត្រីពាក់ព័ន្ធនឹងការគាំទ្រគម្រោងរបស់ខេត្ត និងក្រុមប្រឹក្សាឃុំសង្កាត់ ដើម្បីឱ្យមានសមត្ថភាព ក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាព ដីធ្លី និងជនជាតិដើមភាគតិចឱ្យបានត្រឹមត្រូវដោយខ្លួនឯង ។

## ៦. សកម្មភាពសំខាន់ៗសម្រាប់ឆ្នាំ២០១៧

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦ សម្រាប់ក្រុមការងារកិច្ចការពារសុវត្ថិភាព។
- បន្តរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីតំបន់ងាយរងទទួលផលប៉ះពាល់បរិស្ថាន និងបញ្ជីតំបន់ជនជាតិដើមភាគតិចដោយធ្វើការទំនាក់ទំនង និងសហការជាមួយបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធ ដើម្បីបានប្រើប្រាស់បញ្ជីតំបន់ឃ្លាំមើលទាំងពីរនៅដើមឆ្នាំ២០១៧។
- ចូលរួមតាមការអញ្ជើញរបស់ថ្នាក់ក្រោមជាតិដើម្បីជួសម្របសម្រួលក្នុងវគ្គរំលឹកឡើងវិញស្តីពីគោលការណ៍ណែនាំការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច។
- ពិនិត្យ និងផ្តល់យោបល់បច្ចេកទេសលើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថាន និងឯកសាររបាយការណ៍ស្តីពីវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិច នៃគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។
- ចុះតាមដានការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន និងការអនុវត្តកិច្ចការពារសុវត្ថិភាពដីធ្លី របស់ថ្នាក់ក្រោមជាតិដោយចុះត្រួតពិនិត្យជាក់ស្តែងនៅទីតាំងគម្រោង។
- ចុះត្រួតពិនិត្យឯកសាររបាយការណ៍ដីធ្លីនៃគម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងក្រុង ស្រុក ឆ្នាំ២០១៦។

- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៦ ស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្តនៅដើមឆ្នាំ ២០១៧។
- រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៧ ស្តីពីវឌ្ឍនភាពការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ក្នុងក្របខណ្ឌគម្រោងឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត។
- ចូលរួមសម្របសម្រួលជាមួយអង្គភាពនានាចំណុះលេខាធិការដ្ឋាន គ.ជ.អ.ប. ក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានាដល់មន្ត្រី និងទីប្រឹក្សាពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ។
- រៀបចំរបាយកាយណ៍រីកចម្រើនប្រចាំខែ ប្រចាំឆមាស និងប្រចាំឆ្នាំដាក់ជូនលេខាធិការដ្ឋាន គ.ជ.អ.ប.។

រៀបចំដោយ
ក្រុមការងារកិច្ចការពារសុវត្ថិភាព
នៃលេខាធិការដ្ឋាន គ.ជ.អ.ប.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន
អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
លេខ: ......៤៧៧........./អ.គ.គ.ក

រាជធានីភ្នំពេញ, ថ្ងៃទី..៣.. ខែ.ឧសភា. ឆ្នាំ២០១៧

## សូមគោរពជូន
## ឯកឧត្តមអនុប្រធានប្រតិបត្តិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប.

**តាមរយៈ៖** លោកប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី។

**កម្មវត្ថុ** ៖ របាយការណ៍សង្ខេបស្តីពីលទ្ធផលការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចប្រចាំឆ្នាំ២០១៦ ។

**យោង** ៖ - សេចក្តីសម្រេចលេខ ៧៨ សសរ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច នៃលេខាធិការដ្ឋាន គ.ជ.អ.ប.។

- ផែនការសកម្មភាពរបស់ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តម មេត្តាជ្រាបថា កិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ជាកិច្ចការមួយដ៏សំខាន់បំផុតដែលទាមទារនូវការយកចិត្តទុកដាក់ពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់មន្ត្រីរបស់ទីចាត់ការផែនការ និងវិនិយោគខេត្ត មន្ត្រីការិយាល័យគាំទ្រឃុំ សង្កាត់នៅថ្នាក់ក្រុង ស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងប្រជាពលរដ្ឋដែលជាអ្នកទទួលផលពីគម្រោងផងដែរ។ ក្នុងឆ្នាំ២០១៦នេះ ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដែលមានមន្ត្រី និងទីប្រឹក្សាបានខិតខំបំពេញការងាររបស់ខ្លួនតាមផែនការសកម្មភាព និងថវិកាដែលបានកំណត់ដោយយកចិត្តទុកដាក់ និងមានការទទួលខុសត្រូវខ្ពស់ រហូតទទួលបានលទ្ធផលមានដូចខាងក្រោម៖

១. ក្រុមការងារបានសម្របសម្រួលជាមួយនាយក នាយករងរដ្ឋបាលសាលាខេត្ត នាយក នាយករងទីចាត់ការផែនការ និងវិនិយោគខេត្ត ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់ខេត្ត ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធខេត្ត ទីប្រឹក្សាអភិវឌ្ឍន៍ និងកសាងសមត្ថភាពខេត្ត និងមន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដើម្បីរៀបចំចងក្រងបញ្ជីគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក គម្រោងខេត្ត និងបានធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងឆ្នាំ២០១៦ ជារៀងរាល់ខែដែលថ្នាក់ក្រោមជាតិបានសិក្សាមុននឹងអនុវត្តន៍គម្រោង ក្នុងនេះមាន៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៦ សរុបមានចំនួន **១៦២៦**គម្រោងនៃ**១៥៣៧**ឃុំ សង្កាត់ តម្រូវការសិក្សាបរិស្ថានសរុបចំនួន **៦៥៨**គម្រោង តម្រូវការសិក្សាដីធ្លីសរុបចំនួន**៤៦៥**គម្រោង និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចសរុបមានចំនួន **៨៥**គម្រោង។ គម្រោងដែលស្ថិតនៅ

ក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន៥៦១ និងគម្រោងដែលមានទីតាំងស្ថិតនៅក្នុងបញ្ជីតំបន់ជនជាតិដើមភាគតិចសរុបមានចំនួន ៨៥គម្រោង ។

ខ). គម្រោងមូលនិធិក្រុង ស្រុក នៅឆ្នាំ២០១៦ សរុបមានចំនួន១៩៤គម្រោង នៃ ១៥៤ក្រុង ស្រុក។ ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន ១០៨គម្រោង មិនមានតម្រូវការសិក្សាដីធ្លីទេ និងតម្រូវការសិក្សាជនជាតិដើមភាគតិចសរុបមានចំនួន ២៥គម្រោង។ ចំនួនគម្រោងដែលមានទីតាំងស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបចំនួន ៩៥គម្រោង។

គ). គម្រោងមូលនិធិរាជធានី ខេត្ត ឆ្នាំ២០១៦ សរុបចំនួន ១៤២គម្រោងនៃ ២៤ខេត្ត ក្នុងនោះតម្រូវការសិក្សាបរិស្ថានសរុបចំនួន២២គម្រោង មិនមានតម្រូវការសិក្សាដីធ្លីសរុបទេ និងតម្រូវការសិក្សាវិធានការការពារសុវត្ថិភាពជនជាតិដើមភាគតិចមាន១គម្រោង។ គម្រោងដែលស្ថិតនៅក្នុងតំបន់ងាយរងទទួលនូវផលប៉ះពាល់បរិស្ថានសរុបមានចំនួន ២១គម្រោង។

២. បានពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើគម្រោងមូលនិធិឃុំ សង្កាត់ គម្រោងក្រុង ស្រុក និងគម្រោងរាជធានី ខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានស្ថិតក្នុងបញ្ជីតំបន់ងាយទទួលរងផលប៉ះពាល់បរិស្ថាន និងតំបន់ជនជាតិដើមភាគតិចមុនដេញថ្លៃគម្រោង ដែលខេត្តទាំងអស់បានផ្ញើមកក្រុមការងារ។ គម្រោងដែលបានពិនិត្យ និងផ្តល់យោបល់បច្ចេកទេសមានដូចខាងក្រោម៖

ក). គម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកបរិស្ថានបានចំនួនសរុប ៥៣៦គម្រោង ស្មើនឹង៩៥%នៃចំនួនសរុប ៥៦១គម្រោង និងវិធានការការពារជនជាតិដើមភាគតិចពិនិត្យបានចំនួន៧៣គម្រោង ស្មើនឹង ៨៦%នៃចំនួន៨៥គម្រោង ។ ក្នុងនេះមានគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងគម្រោងកាត់បន្ថយភាពក្រីក្រនៅជុំវិញបឹងទន្លេសាបផងដែរ។

ខ).គម្រោងមូលនិធិក្រុង ស្រុក ផ្នែកបរិស្ថានបានចំនួនសរុប ៥៤គម្រោង ស្មើនឹង៥៧%នៃចំនួនសរុប៩៥គម្រោង និងពិនិត្យវិធានការការពារជនជាតិដើមភាគតិចបានចំនួន ៨គម្រោង ស្មើនឹង៣២%នៃចំនួន ២៥គម្រោង ។

គ).បានពិនិត្យបរិស្ថានគម្រោងមូលនិធិខេត្ត លើឯកសាររបាយការណ៍វិភាគផលប៉ះពាល់បរិស្ថានពិនិត្យបានចំនួនសរុប ១៨គម្រោង ស្មើនឹង៨៦%នៃចំនួនសរុប ២១គម្រោង និងពិនិត្យគម្រោងជនជាតិដើមភាគតិចបានចំនួន ១គម្រោង ស្មើ១០០%នៃចំនួន ១គម្រោង។

៣. បានចុះត្រួតពិនិត្យឯកសារនិងរបាយការណ៍សិក្សាដីធ្លីរបស់គម្រោងឃុំសង្កាត់ឆ្នាំ២០១៥ នៅទីចាត់ការផែនការ និងវិនិយោគខេត្តចំនួនប្រាំបី ព្រមទាំងបានចុះទៅដល់ឃុំ សង្កាត់ និងទីតាំងគម្រោង។ បានត្រួតពិនិត្យគម្រោង ដីធ្លីសរុបចំនួន ១៤០គម្រោង ស្មើនឹង៦៣%នៃគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវការសិក្សាដីធ្លីសរុបចំនួន២២២គម្រោង។ ដំណើរការនៃការត្រួតពិនិត្យឯកសារ និងរបាយការណ៍ដីធ្លីនេះ នៅទីចាត់ការផែនការ និងវិនិយោគខេត្ត និងសាលាឃុំ សង្កាត់ ហើយបានផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ នៅតាមទីតាំងគម្រោង ដោយជួបជាមួយប្រជាពលរដ្ឋ

ដែលជាអ្នកទទួលផលពីគម្រោង។ បន្ទាប់ពីបញ្ចប់រាល់ការពិនិត្យឯកសារ ក្រុមការងារបានប្រជុំឆ្លុះបញ្ចាំងបង្ហាញពីលទ្ធផលដែលបានរកឃើញលើចំណុចខ្វះខាត និងផ្តល់អនុសាសន៍ ដល់អ្នកពាក់ព័ន្ធសម្រាប់កែលម្អនូវការអនុវត្តនៅឆ្នាំ២០១៧។

